មើលវីដេអូ ភាគទី ១៨

# អប្បមញ្ញាចេតសិក ២

១ - ករុណាចេតសិក ២ - មុទិតាចេតសិក

**អប្បមាណេសុ សត្តេសុ ភវតីតិ** = **អប្បមញ្ញា** ធម្មជាតិឈ្មោះថា អប្បមញ្ញា ព្រោះអត្ថថា ប្រព្រឹត្តទៅក្នុងសត្វមិនមានប្រមាណ។

ស្កេនដើម្បីមើលមេរៀន

San Sochea Official

# ២៣ - ករុណាចេតសិក (Compassion)

បរទុក្ខេ សតិ សាធូនំ ហទយខេទំ ករោតីតិ = ករុណា

ធម្មជាតិណា កាលសត្វដទៃមានទុក្ខ រមែងធ្វើនូវសេចក្តី

អាណិតអាសូរដល់សាធុជនទាំងឡាយ ព្រោះហេតុនោះ

ធម្មជាតិនោះ ឈ្មោះថា ករុណា។

ករុណា មាន ទុក្ខិតសត្តប្បញ្ញត្តិ (សេចក្តីទុក្ខរបស់សត្វ)

ជាអារម្មណ៍។

# លក្ខណាទិចតុក្កៈរបស់ករុណា

| | |
|---|---|
| ១ - បរទុក្ខាបនយការមតាលក្ខណា | មានសេចក្ដីប្រាថ្នាជួយបំបាត់ទុក្ខអ្នកដទៃ (អាណិតអាសូរ) ជាលក្ខណៈ |
| ២ - បរទុក្ខាសហានរសា | មានការអត់ធន់មិនបានចំពោះសេចក្ដីទុក្ខអ្នកដទៃ ជាកិច្ច |
| ៣ - អវិហឹសា បច្ចុប្បដ្ឋានា | មានការមិនបៀតបៀន ជាអាការប្រាកដ |
| ៤ - ទុក្ខាភិភូតានំ អានាថភាវទស្សនបទដ្ឋានា | មានការឃើញសត្វដែលទុក្ខគ្របសង្កត់ហើយមិនមានទីពឹង ជាហេតុជិត។ |

# សម្បត្តិ និង វិបត្តិ របស់ករុណា ៖

វិហឹសូបសមោ សម្បត្តិ មានការចូលទៅរម្ងាប់នូវសេចក្តីបៀតបៀន ជាសម្បត្តិ

សោកសម្ភវោ វិបត្តិ មានការកើតឡើង នៃសេចក្តីសោក (ងាយនឹងឲ្យសោកកើតឡើង) ជាវិបត្តិ

គេហសិតំ ទោមនស្សំ អាសន្នបច្ចត្ថិកា មានទោមនស្ស (ការខូចចិត្ត) ដែលអាស្រ័យកាមគុណ ជាសត្រូវជិត

វិហឹសា ទូរបច្ចត្ថិកា មានការបៀតបៀនសត្វ ជាសត្រូវឆ្ងាយ។

# ២៤ - មុទិតាចេតសិក

(Appreciative or Sympathetic joy)

**មោទន្តិ ឯតាយាតិ** = **មុទិតា** បុគ្គលរមែង ត្រេកអរ (ចំពោះសេចក្តីសុខ ឬសម្បត្តិរបស់អ្នកដទៃ) ដោយធម្មជាតិនេះ ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា **មុទិតា**។

**មុទិតា** មាន **សុខិតសត្តប្បញ្ញត្តិ** (សេចក្តីសុខ ឬសម្បត្តិរបស់សត្វ) ជាអារម្មណ៍។

# លក្ខណាទិចតុក្កៈរបស់មុទិតា

១ - បរសម្បត្តិអនុមោទនលក្ខណា — មានការត្រេកអររីករាយ (ស្ងរសើរ) ចំពោះសម្បត្តិរបស់អ្នកដ័ទៃ ជាលក្ខណៈ

២ - អនិស្សាយនរសា — មានការមិនច្រណែន ជាកិច្ច

៣ - អរតិវិឃាតបច្ចុប្បដ្ឋានា — មានការកំចាត់បង់នូវអរតិ (ការមិនត្រេកអរ) ជាអាការប្រាកដ

៤ - បរសម្បត្តិទស្សនបទដ្ឋានា — មានការឃើញសម្បត្តិរបស់សត្វដ័ទៃ ជាហេតុជិត។

# សម្បត្តិ និង វិបត្តិ របស់ មុទិតា ៖

អរតិវូបសមោ សម្បត្តិ មានការចូលទៅរម្ងាប់នូវអរតិ (សេចក្តីមិនត្រេកអរ) ជាសម្បត្តិ

បហាសសម្ភវោ វិបត្តិ មានការសើចសប្បាយ (ក្អាកក្អាយភ្លើតភ្លើន) ជាវិបត្តិ

គេហសិតំ សោមនស្សំ អាសន្នបច្ចត្ថិកា មានសោមនស្សដែលអាស្រ័យនឹងកាមគុណ ជាសត្រូវជិត

អរតិទូរបច្ចត្ថិកា មានការមិនត្រេកអរ (នឹងសុខ ឬសម្បត្តិរបស់អ្នកដទៃ) ជាសត្រូវឆ្ងាយ។

# អប្បមញ្ញា (ឬព្រហ្មវិហារ) ៤

១- មេត្តា អង្គធម៌ គឺ អទោសចេតសិក

២- ករុណា អង្គធម៌ គឺ ករុណាចេតសិក

៣- មុទិតា អង្គធម៌ គឺ មុទិតាចេតសិក

៤- ឧបេក្ខា អង្គធម៌ គឺ តត្រមជ្ឈត្តតាចេតសិក។